ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

អាជ្ញាធរអគ្គិសនីកម្ពុជា
ELECTRICITY AUTHORITY OF CAMBODIA
លេខ ៖ ០៦ ២៧ សំ.រ -១២-អអក

# សេចក្តីសម្រេចកែសម្រួលលើកទី៥
# លើឯកសារអាជ្ញាប័ណ្ណលេខ ១៣៧ ឯអ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០៦
# សម្រាប់ក្រុមហ៊ុន ម៉េង សុខឡេង ខនស្រ្តាក់សិន & អេឡិកទ្រិក

# DECISION ON THE FIFTH REVISION
# OF THE LICENSE DOCUMENT No. 137 LD DATED JUNE 28, 2006
# FOR MENG SOKLENG CONSTRUCTION & ELECTRIC CO., Ltd

## អាជ្ញាធរអគ្គិសនីកម្ពុជា
## ELECTRICITY AUTHORITY OF CAMBODIA

-អនុវត្តតាមមាត្រា ៧ និង ៣៥ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១

- In exercise of the powers conferred by Article 7 and 35 of the Electricity Law promulgated by the Royal Decree NS/RKM/0201/03, dated February 02, 2001.

-យោងឯកសារអាជ្ញាប័ណ្ណលេខ ១៣៧ ឯអ ដែលអាជ្ញាធរអគ្គិសនីកម្ពុជាចេញឲ្យក្រុមហ៊ុន ម៉េង សុខឡេង ខនស្រ្តាក់សិន & អេឡិកទ្រិក នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០៦

- In accordance with License Documents No. 137 LD issued by Electricity Authority of Cambodia on June 28, 2006 to Meng Sokleng Construction & Electric Co., Ltd.

-យោងពាក្យស្នើសុំបង្កើនអាណត្តិអាជ្ញាប័ណ្ណរបស់ក្រុមហ៊ុន ម៉េង សុខឡេង ខនស្រ្តាក់សិន & អេឡិកទ្រិក ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១១

- In accordance with the application of Meng Sokleng Construction & Electric Co., Ltd for increasing of term of license, dated October 10, 2011.

- យោងកំណត់បង្ហាញសុំបង្កើនអាណត្តិអាជ្ញាប័ណ្ណរបស់លេខាធិការដ្ឋានលេខ ០០៧-១២-លជ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១២

- In accordance with the request for increasing term of Secretariat Office No.007-12 dated January 19, 2012

-យោងតាមការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងសាធារណជន ដែលបានធ្វើចាប់ពីថ្ងៃទី២០ ខែមេសា ឆ្នាំ២០១២ ដល់ថ្ងៃទី ៣០ ខែឧសភា ឆ្នាំ២០១២

- In accordance with the consultation with concerned parties and public, made from April 20, 2012 to May 30, 2012.

-យោងតាមការអនុម័តរបស់សម័យប្រជុំ **អាជ្ញាធរអគ្គិសនីកម្ពុជា** លើកទី២៣០ នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១២

- In accordance with the decision of Electricity Authority of Cambodia's Session No.230 dated June 29, 2012.

## សម្រេច

## DECIDES

| | |
|---|---|
| **ប្រការ១** | **Article 1** |
| ដោយក្រុមហ៊ុន **ម៉េង សុខឡេង ខនស្រ្តាក់ស៊ិន & អេឡិកទ្រិក** (បន្ទាប់ពីនេះហៅថា **"អ្នកកាន់អាជ្ញាប័ណ្ណ"**) មានមធ្យោបាយធ្វើសេវាកម្មអគ្គិសនីរបស់ខ្លួនស្របតាមស្តង់ដាបច្ចេកទេសអគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជា អាជ្ញាធរអគ្គិសនីកម្ពុជាសម្រេចកែសម្រួលឯកសារអាជ្ញាប័ណ្ណលេខ ១៣៧ ឯអ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០៦ ដែលបានផ្តល់ជូនអ្នកកាន់អាជ្ញាប័ណ្ណ ដោយបង្កើនអាណត្តិអាជ្ញាប័ណ្ណពី០៧(ប្រាំពីរ)ឆ្នាំ ទៅ ២៥(ម្ភៃប្រាំ)ឆ្នាំ ។ អាណត្តិថ្មីរបស់អាជ្ញាប័ណ្ណនេះមានរយៈពេល ២៥(ម្ភៃប្រាំ)ឆ្នាំ គិតចាប់ពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ ២០០៦ និងអាចស្នើសុំបន្តទៀត ឬស្នើសុំកែសម្រួលលើកលែងតែត្រូវដកហូតដោយអនុលោមតាមល័ក្ខខ័ណ្ឌនៃអាជ្ញាប័ណ្ណនេះ ។ | As **Meng Sokleng Construction & Electric Co.,Ltd** (herein after referred to as **"Licensee"**) has its facilities in accordance with Electric Power Technical Standards of the Kingdom of Cambodia, EAC decides to revise license document No. 137 LD dated June 28, 2006 granted to licensee by increasing term of license from 07 (Seven) years to 25 (Twenty five) years . The new term of the license shall be 25 (Twenty five) years from June 28, 2006 and may be renewed for further periods unless revoked earlier in accordance with the conditions of license. |
| **ប្រការ២** | **Article2** |
| ខ្លឹមសារ និងល័ក្ខខ័ណ្ឌដទៃទៀតនៃឯកសារអាជ្ញាប័ណ្ណលេខ ១៣៧ ឯអ ត្រូវស្ថិតនៅជាធរមានដដែល ។ | The other contents and conditions of the license document No. 137 LD shall remain in force. |
| **ប្រការ៣** | **Article 3** |
| សេចក្តីសម្រេចនេះ ត្រូវចាត់ទុកជាផ្នែកមួយនៃឯកសារអាជ្ញាប័ណ្ណលេខ ១៣៧ ឯអ ។ | This decision shall be considered as a part of the license document No. 137 LD. |
| **ប្រការ៤** | **Article 4** |
| សេចក្តីសម្រេចនេះ ត្រូវចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ | The decision shall come into force from the date of signing. |
| **ប្រការ៥** | **Article 5** |
| អ្នកកាន់អាជ្ញាប័ណ្ណត្រូវផ្ញើសេចក្តីសម្រេចនេះទៅតម្កល់ទុកបន្ថែមនៅតាមទីកន្លែងដែលឯកសារអាជ្ញាប័ណ្ណលេខ ១៣៧ ឯអ បានតម្កល់ទុកពីមុន ដើម្បីឲ្យឯកសារអាជ្ញាប័ណ្ណលេខ១៣៧ ឯអ ដែលតម្កល់មានការកែសម្រួលជាថ្មីស្របតាមសេចក្តីសម្រេចនេះ ។ | The licensee shall send this decision to deposit additionally at the places, where the license document No. 137 LD has been deposited in order that the deposited license document No.137 LD is in conformity with this decision. |

ភ្នំពេញ, ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១២

Phnom Penh, June 29, 2012

**ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា**

CHAIRMAN OF ELECTRICITY AUTHORITY OF CAMBODIA

**បណ្ឌិត.ទី នរិន្ទ**